**សម្រេច**

**មាត្រា ១** : ត្រូវបានតែងតាំងអស់លោកដូចរាយឈ្មោះខាងក្រោម ជាជំនួយការទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើប្រធាននាយកដ្ឋាន ៖

- លោក **ម៉ុន ណារិទ្ធិ** ជំនួយការឯកឧត្តម **ញឹម វណ្ណដា**
- លោក **ឃឹម សារិទ្ធ** ជំនួយការឯកឧត្តម **ហង់ ជួន**
- លោក **សុខ ទីរៈ** ជំនួយការឯកឧត្តម **ចាន់ គិន**
- លោក **ម៉ុន ខេង** ជំនួយការលោកជំទាវ **ហូ ណាន**
- លោក **អ៊ិត ចាន់ឡុង** ជំនួយការឯកឧត្តម **ម៉ិល ណាល់**

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *

## ២ - សេចក្តីសម្រេច

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

**សេចក្តីសម្រេចលេខ ១៣ សសរ**

**ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំ និងគ្រប់គ្រងតំបន់ប៉ៃលិន**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ កែ កក្កដា ឆ្នាំ ១៩៩៤ ។
- យោងតាមសំណូមពរការងារចាំបាច់ ។

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មាធិការរៀបចំ និងគ្រប់គ្រងតំបន់ប៉ៃលិន ដែលមានសមាសភាពដូចខាងក្រោម ៖

១ - ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ ប្រធាន

២ - ឯកឧត្តម **ហូ សុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៣ - លោកឧត្តមសេនីយ៍ **ជា សារ៉េត** មេបញ្ជាការរងយោធភូមិភាគ ២ អនុប្រធាន

៤ - លោកឧត្តមសេនីយ៍ **អ៊ុក គីមលេខ** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អនុប្រធាន

៥ - លោកឧត្តមសេនីយ៍ **ខឹម ជាសុខឿន** មេបញ្ជាការរងយោធភូមិភាគពិសេស អនុប្រធាន

៦ - លោកឧត្តមសេនីយ៍ **ចំរើន ជាតិ** អនុប្រធានយោធភូមិភាគទី ៥ អនុប្រធាន

៧ - លោកឧត្តមសេនីយ៍ **ហង្ស យុទ្ធ** អនុប្រធានទី ១ នាយកដ្ឋានកណ្តាលសន្តិសុខ អនុប្រធាន

៨ - លោកឧត្តមសេនីយ៍ **ជា សារិន** នាយការិយាល័យទី ៣ អគ្គសេនាធិការ អនុប្រធាន

៩ - លោកឧត្តមសេនីយ៍ **ថ្លាំ មរណៈ** អនុប្រធាន

១០ - លោក **ណាំ ទុំ** អភិបាលរងទី២ ខេត្តបាត់ដំបង អនុប្រធានប្រចាំការ សមាជិក

១១ - លោក **ថ្លាជ្ញ ចន្ទ** អគ្គនាយករងរដ្ឋបាល សមាជិក

១២ - លោក **ជួន ខ្វា** ប្រធានមន្ទីរសាធារណការខេត្តបាត់ដំបង សមាជិក

១៣ - លោក **កុយ ដោក** នាយផ្នែកការិយាល័យទី ១ អគ្គសេនាធិការ សមាជិក

១៤ - លោក **ជឹម តៀយ** មេបញ្ជាការសឹករងតំបន់ប៉ៃលិន សមាជិក

១៥ - លោក **សុខ ចំរើន** អនុប្រធាននាយកដ្ឋាន នគរបាលការពារ សមាជិក

១៦ - លោក **ជួន ចោម** បញ្ជាការកងរាជអាវុធហត្ថតំបន់ប៉ៃលិន សមាជិក

១៧ - លោក **ឆេព ទិចិត្រ** នាយរងការិយាល័យទី ៥ អគ្គសេនាធិការ សមាជិក

១៨ - លោក **អៅ គីមឈួន** ទីប្រឹក្សា ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៩ - លោក **ម៉ែន សិទ្ធី** អនុប្រធាននាយកដ្ឋានសុខាភិបាលក្រសួងមហាផ្ទៃ សមាជិក

២០ - លោក **ឈឹម នី** មន្ត្រីនាយកដ្ឋានរដ្ឋបាលទូទៅ សមាជិក

២១ - លោក **ថ្នាក់ ស៊ៀប** អនុប្រធានមន្ទីរសេដ្ឋកិច្ច ហិរញ្ញវត្ថុខេត្តបាត់ដំបង សមាជិក

២២ - លោក **ស ប៊ុនធូ** អនុប្រធានមន្ទីរសុខាភិបាលខេត្ត បាត់ដំបង សមាជិក

២៣ - លោក **សោម សាម៉ី** ប្រធានការិយាល័យទី ៣ រាជអាវុធហត្ថ ខេត្តតាកែវ សមាជិក

២៤ - លោក **ខ្នាក់ សន់** អភិបាលរងស្រុករតនមណ្ឌល សមាជិក

២៥ - លោក **ពិន ម៉ិត** ប្រធានការិយាល័យភូមិបាលស្រុក រតនមណ្ឌល សមាជិក

២៦ - លោក **ព្រហ្ម សុខុន** ស្នងការរដ្ឋាននគរបាលខេត្ត បាត់ដំបង សមាជិក

២៧ - លោក **សំ គី** ស្នងការរដ្ឋាននគរបាលខេត្ត បាត់ដំបង សមាជិក

**ប្រការ ២** : គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ :

– សហការ និងដឹកនាំបញ្ជាកងកម្លាំងប្រដាប់អាវុធ ដើម្បីការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់ប៉ៃលិន ។

– រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលដែនដី និងទំរង់បែបបទសុំបង្កើតថ្នាក់ រដ្ឋបាលប៉ៃលិន ។

– កសាងហេដ្ឋារចនាសម្ព័ន្ធ គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ ដោះស្រាយ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ យកចិត្តទុក ដាក់ដល់ការងារអប់រំ សង្គមកិច្ច សុខាភិបាល ថែរក្សាសម្បត្តិវប្បធម៌ជាតិ និង បរិដ្ឋានធម្មជាតិ ។

– បំពេញកិច្ចការផ្សេង ៗ ទៀតដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

**ប្រការ ៣** : គណៈកម្មាធិការនេះមានសិទ្ធិ :

– លើកសំណើរៀបចំមន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធដែលស្ថិតក្នុង សមត្ថកិច្ចរបស់ខ្លួន ។

- បង្កើតអនុគណៈកម្មការនានាជាជំនួយការ ។
- សហការជាមួយអាជ្ញាធរខេត្តបាត់ដំបង ជ្រើសរើសមន្ត្រីជំនាញពីមន្ទីរនានានៅក្នុងខេត្ត ដើម្បីយកមកបំរើការងាររបស់គណៈកម្មាធិការ ។
- លើកគំរោងសកម្មភាពការងារ និង ថវិកាដើម្បីសុំការសំរេចពីរាជរដ្ឋាភិបាលតាមរយៈក្រសួងមហាផ្ទៃ ។
- បែងចែកដីលំនៅដ្ឋានដល់ប្រជាពលរដ្ឋដែលទៅរស់នៅតំបន់ប៉ៃលិន ។

**ប្រការ ៤ :** គណៈបញ្ជាការសមរភូមិតំបន់ប៉ៃលិន និងគណៈកម្មាធិការនេះត្រូវសហការគ្នាអោយបានល្អ ដើម្បីបេសកកិច្ចដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

**ប្រការ ៥ :** គណៈកម្មាធិការនេះ មានត្រារបស់ខ្លួនដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ ៦ :** អនុញ្ញាតអោយគណៈកម្មាធិការនេះមានគណនីដោយឡែក សំរាប់បំរើសំណូមពរការងារ ។

**ប្រការ ៧ :** គណៈកម្មាធិការនេះត្រូវចំណុះផ្ទាល់ក្រសួងមហាផ្ទៃ និង បំពេញការងាររហូតដល់មានការប្រកាសជាផ្លូវការថ្នាក់រដ្ឋបាលប៉ៃលិន ។

**ប្រការ ៨ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អភិបាលខេត្តបាត់ដំបង និង ឯកឧត្តម អស់លោក ក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *